ធនាគារពិភពលោកប្រចាំកម្ពុជា

# ព្រេង & ឧស្ម័ន



លេខ ១៧ | កំណត់សំគាល់ត្រួសៗអំពីវិស័យប្រេងឥន្ធនៈ | ខែ សីហា/កញ្ញា ឆ្នាំ ២០០៩

# តើតម្លៃប្រេងឡើងប្រៀបដូចកាំជ្រួច ហើយពេលធ្លាក់ចុះវិញដូចរោមសត្វឬ?

***"បាញ់បង្ហោះឡើងដូចជាកាំជ្រួច រសាត់អណ្តែតធ្លាក់ចុះក្រោមដូចជារោមសត្វនៅក្នុងខ្យល់" ឬប្រហាក់ប្រហែលពេលនេះ វាជាទស្សនៈនៃតម្លៃផលិតផលប្រេង។ ទស្សនៈនេះបានក្លាយជាចំណាប់អារម្មណ៍សាធារណរបស់ពិភពលោកនៅក្នុងឆ្នាំ ២០០៨ នៅពេលដែលតម្លៃ ប្រេងឥន្ធនៈនៅលើពិភពលោកបានកើនឡើងនៅក្នុងរយៈពេល៦ខែដំបូង ហើយដែលតម្លៃនេះទើបតែធ្លាក់ចុះគួរឱ្យកត់សម្គាល់មកនៅ មួយភាគបីនៃតម្លៃអតិបរមារបស់វានៅក្នុងរយៈ៥ខែបន្ទាប់។ សេចក្តីសង្ខេបនេះពិភាក្សាអំពីកត្តាផ្សេងៗដែលមានឥទ្ធិពលលើទំនាក់ទំនងរវាងតម្លៃនៃផលិតផលប្រេងនៅលើទីផ្សារពិភពលោក និងទីផ្សារលក់រាយនៅក្នុងស្រុក។***

អ្នកបើកបរតាក់ស៊ីម្នាក់បានត្អូញត្អែរអំពីតម្លៃប្រេងសាំងនៅក្នុងប្រទេសកម្ពុជាកាលពីខែតុលាឆ្នាំ២០០៨ [១] ថា "កើនឡើងដូច ជាសត្វទន្សាយលោតតែឥឡូវធ្លាក់ចុះវិញដូចជាសត្វអណ្តើកវារ"។ តើតម្លៃផលិតផលប្រេងកើនឡើងលឿននៅពេលដែលតម្លៃប្រេងនៅលើពិភពលោកកើនឡើង ហើយធ្លាក់ចុះយឺតៗនៅពេល ដែលតម្លៃប្រេងពិភពលោកធ្លាក់ចុះដូច្នេះឬ? បើដូច្នេះមែន តើនេះគឺដោយសារតែបញ្ហាផ្គត់ផ្គង់រូបវ័ន្តស្របច្បាប់ ដូចជាតម្លៃកែតម្រូវបញ្ជីសារពើភ័ណ្ឌឬយ៉ាងណា? ឬក៏ជាគំរូមិនប្រក្រតីមួយនៃលទ្ធផលអាកប្បកិរិយាទីផ្សារដែលគ្មានលក្ខណៈប្រកួតប្រជែង (ដែលក្នុងករណីនេះគួរតែអំពាវនាវឱ្យរដ្ឋាភិបាលជួយធ្វើអន្តរាគម)? "កាំជ្រួចនិងរោមសត្វ" គឺជាប្រធានបទនៃការពិភាក្សានិងការសិក្សា នៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ សេចក្តីសង្ខេបនេះ ពិនិត្យមើលឡើងវិញលើភស្តុតាងនៅក្នុងប្រទេសដទៃទៀត និងការពន្យល់ដែលអាចធ្វើទៅបានសម្រាប់ទំនាក់ទំនងនៃចលនាតម្លៃប្រេងបែបនេះ។

## គម្លាតនៃតម្លៃ

ដោយសារតែមានដំណាក់កាលជាច្រើននៅក្នុងប្រព័ន្ធផ្គត់ផ្គង់មុន នឹងផលិតផលប្រេងត្រូវបានលក់ចេញទៅឱ្យអតិថិជន វាត្រូវការពេលវេលាមុននឹងបម្រែបម្រួលនៃតម្លៃប្រេងឆៅត្រូវបានបញ្ជូនទៅកាន់ទីផ្សារលក់រាយ។ ករណីសម្រាប់ប្រទេសកម្ពុជា ដូចដែលបានពន្យល់នៅក្នុង [២] បញ្ហានេះគឺជាគម្លាតរវាងពេលវេលា ដែលបម្រែបម្រួលនៃតម្លៃផលិតផលចំរាញ់កើតឡើងនៅក្នុងប្រទេសសិង្ហបុរី ថៃឡង់ដ៍ ឬប្រទេសដទៃទៀត ដែលប្រទេសកម្ពុជានាំចូលផលិតផលប្រេង និងពេលវេលាដែលបម្រែបម្រួលនៃតម្លៃត្រូវបានឆ្លុះបញ្ចាំងនៅឯទីផ្សារលក់រាយក្នុងប្រទេសកម្ពុជា។

កត្តាកំណត់ដ៏សំខាន់មួយនៃគម្លាតថ្លៃ គឺអត្រានៃការបំពេញទំនិញបន្ថែមក្នុងបញ្ជីសារពើភ័ណ្ឌ។ ក្រុមហ៊ុនភាគច្រើនប្រើប្រព័ន្ធគណនេយ្យចូលមុន-ចេញមុន។ នៅពេលដែលតម្លៃកំពុងធ្លាក់ចុះ ទំនិញដំបូងនៅក្នុងស្តុកនៃផលិតផលចំរាញ់ នឹងត្រូវបានទិញចូលនៅពេលដែលតម្លៃឡើងកាន់តែខ្ពស់ ហើយផ្ទុយមកវិញនៅពេលដែលតម្លៃកំពុងកើនឡើងទំនិញដំបូងនៅក្នុងស្តុកនឹងត្រូវបានគេទិញចូល នៅពេលដែលតម្លៃកាន់ចុះកាន់តែទាប។ ប្រសិនបើការដាក់បំពេញទំនិញបន្ថែមក្នុងបញ្ជីសារពើភ័ណ្ឌធ្វើបានលឿនជាងនៅពេលដែលតម្លៃកំពុងកើនឡើងជាងនៅពេលដែលវាកំពុងធ្លាក់ចុះ (គឺការបំពេញបញ្ជីសារពើភ័ណ្ឌលឿនអាចកើតឡើង ប្រសិនបើបញ្ជីសារពើភ័ណ្ឌដំបូងមានតិច ប្រសិនបើបរិមាណលក់មានកំរិតខ្ពស់ ឬទាំងពីរ) ដែលនឹងបង្កឱ្យមានបាតុភូតនៃកាំជ្រួច និងរោមសត្វ។

ការថយចុះគិតជាភាគរយលើទីផ្សារប្រេងឆៅលើពិភពលោកជាទូទៅមិនបានបង្ហាញអំពីការថយចុះគិតជាភាគរយដូចគ្នាសម្រាប់តម្លៃលក់រាយនោះទេ។ ដំបូងតម្លៃផលិតផលប្រេងឆៅនិងប្រេង

ចំរាញ់ ត្រូវបានគ្រប់គ្រងដោយកំលាំងផ្គត់ផ្គង់និងកំលាំងតំរូវការផ្សេងៗគ្នា។ ជាធម្មតា ព័ត៌មានសំខាន់ គឺនិយាយអំពីតម្លៃប្រេងឆៅស្តង់ដាមួយ ហើយក្នុងរយៈពេលដ៏ខ្លីមួយ តម្លៃប្រេងឆៅអាចកើនឡើងក្នុងខណៈដែលតម្លៃដែលគេដឹងឮ (spot price) (តម្លៃមិនទាន់បង់ពន្ធ net-of-tax) នៃផលិតផលប្រេងចំរាញ់ ធ្លាក់ចុះ ហើយបញ្ច្រាសមកវិញ។ ទីពីរ បម្រែបម្រួលនៃអត្រាប្តូរប្រាក់ មានឥទ្ធិពលលើតម្លៃនៅក្នុងស្រុក ទោះបីជាតម្លៃប្រេងនៅលើពិភពលោកនៅថេរក៏ដោយ ទោះជាសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្ពស់និងទោះបីជាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារមានស្ថេរភាពក៏ដោយ។ ទីបី តម្លៃផលិតផលប្រេងលក់រាយ រួមបញ្ចូលទាំងពន្ធដែលជានិច្ចកាលមិនត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌគិតជាភាគរយ។ នៅក្នុងប្រទេសកម្ពុជា តម្លៃយោងសម្រាប់ផលិតផលប្រេងចំរាញ់ ត្រូវបានជាប់គាំងចាប់ពីឆ្នាំ ២០០៤ មក ដែលផ្លាស់ប្តូរយ៉ាងមានប្រសិទ្ធិភាព នូវពន្ធផ្សេងៗ ដែលបានកំណត់ជាភាគរយមានតែនាម ទៅជាពន្ធជាក់លាក់ គឺស្ថេរភាពនៃប្រាក់រៀល និងឯករាជ្យភាពនៃចលនាតម្លៃប្រេងលើពិភពលោក។ ទីបួន តម្លៃនៃផលិតផលប្រេងចំរាញ់ដឹកជញ្ជូនតាមនាវា រថភ្លើង និងរថយន្ត ដែលត្រូវបានរួមបញ្ចូលទាំងតម្លៃលក់រាយពឹងផ្អែកតែទៅលើតម្លៃប្រេងឥន្ធនៈមួយផ្នែកប៉ុណ្ណោះ មិនបានបែងចែកជាពីរផ្នែកម្តងទៀតទេ ប្រសិនបើតម្លៃប្រេងលើពិភពលោកបែងចែកជាពីរផ្នែកទៀតនោះ។

ការប្រៀបធៀបតម្លៃដឹកចូលផែមិនទាន់គិតពន្ធនៅប្រទេសសិង្ហបុរី និងតម្លៃលក់រាយ (រួមទាំងពន្ធ) នៅទីក្រុងភ្នំពេញ សម្រាប់ប្រេងសាំងនិងប្រេងម៉ាស៊ូត មានបង្ហាញនៅក្នុងរូប១។ តម្លៃលក់រាយនៅកម្ពុជាមានលក្ខណៈល្អប្រសើរនិងបង្ហាញពីអស្ថេរភាពតិចជាងតម្លៃនៅក្នុងប្រទេសសិង្ហបុរី។ ដូចដែលបានពន្យល់ខាងលើរួចមកហើយ ផ្នែកពន្ធដារនៅក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់ជាពិសេស ហើយមិនប្រែប្រួលតាមរយៈពេលដែលបានបង្ហាញនៅក្នុងរូបនេះទេ។ តម្លៃប្រេងម៉ាស៊ូតធ្លាក់ចុះក្នុងកំរិតដូចគ្នាពីតម្លៃខ្ពស់បំផុតក្នុងឆ្នាំ២០០៨ មកដល់ខែមេសាឆ្នាំ ២០០៩ នៅក្នុងប្រទេសសិង្ហបុរីនិងនៅភ្នំពេញ ក៏ប៉ុន្តែបានធ្លាក់ចុះច្រើនជាងចំពោះប្រេងសាំង គឺប្រហែល ០,០៨ ដុល្លារ ក្នុងមួយលីត្រនៅភ្នំពេញ។ គ្មានភស្តុតាងច្បាស់លាស់អំពីកាំជ្រួចនិងរោមសត្វទេ។

## ប្រតិកម្មនៅក្នុងឆ្នាំ២០០៨

អតិថិជនជាច្រើននៅលើពិភពលោក បានដឹងអំពីល្បឿននៃកំណើនតម្លៃប្រេងនៅក្នុងឆមាសទីមួយឆ្នាំ២០០៨។ សូម្បីតែនៅក្នុងទីផ្សារមួយដែលមានទំហំធំនិងមានលក្ខណៈប្រកួតប្រជែងដូចជាទីផ្សារប្រេងសាំងនៅសហរដ្ឋអាមេរិក ការស្ទាបស្ទង់មួយដែលបាន ធ្វើឡើងកាលពីខែកក្កដាឆ្នាំ២០០៨ បានរកឃើញថាច្រើនជាងពាក់កណ្តាលនៃអតិថិជនដែលគេបានធ្វើការស្ទាបស្ទង់បានស្តីបន្ទោសអំពីតម្លៃដែលកំណត់ដោយក្រុមហ៊ុនប្រេងនិងប្រទេសផលិតប្រេង ក៏ដូចជាកង្វះចំណាត់វិធានការដែលមានប្រសិទ្ធិភាពរបស់រដ្ឋាភិបាល ចំពោះតម្លៃប្រេងដែលថ្លៃនេះ [៣]។

រូប១ : តម្លៃប្រេងសាំងនិងប្រេងម៉ាស៊ូតប្រចាំខែនៅប្រទេសសិង្ហបុរីនិងនៅភ្នំពេញ



នៅក្នុងប្រទេសកេនយ៉ា ដែលតម្លៃប្រេងត្រូវបានកំណត់ដោយកំលាំងទីផ្សារ រដ្ឋមន្ត្រីថាមពល បានប្រកាសនៅក្នុងខែកញ្ញាឆ្នាំ ២០០៨ ថា ក្រសួងរបស់លោក នឹងចាប់ផ្តើមផ្សព្វផ្សាយយុទ្ធនាការមួយតាមរយៈបណ្តាញឃោសនា ដើម្បីបង្ខំឱ្យអ្នកលក់ប្រេងឥន្ធនៈបញ្ចុះតម្លៃប្រេងឱ្យមកនៅត្រឹម ១០ ស៊ីលីង (ស្មើនឹង ៥៧៦ រៀល) ក្នុងមួយលីត្រ។ នៅខែតុលា ឆ្នាំ ២០០៨ រដ្ឋមន្ត្រីថាមពលបាននិយាយថា លោកមិនពេញចិត្តនឹងការឆ្លើយតបរបស់ក្រុមហ៊ុនប្រេងចំពោះសំណើរបស់រដ្ឋាភិបាលដែលសុំឱ្យបញ្ចុះតម្លៃប្រេងនេះទេ ហើយបានពន្យារលទ្ធភាពនៃការត្រួតពិនិត្យតម្លៃដែលណែនាំសារជាថ្មី [៤]។

រដ្ឋាភិបាលប្រទេសហ្វីលីពីនបានប្រកាសនៅក្នុងឆ្នាំ២០០៨ថា ក្រុមការងាររួមមួយរបស់នាយកដ្ឋានថាមពល និងយុត្តិធម៌នឹងធ្វើការស៊ើបអង្កេត ប្រសិនបើរឿងក្តីផ្សេងៗនៃប្រព័ន្ធទីផ្សារដែល មិនយុត្តិធម៌ និងការកំណត់តម្លៃលើស អាចនឹងត្រូវបានរៀបចំឡើង ដើម្បីប្តឹងក្រុមហ៊ុនប្រេងកំពូលចំនួនបី ដែលមានភាគហ៊ុននៅលើទីផ្សាររួមចំនួន ៨៣ ភាគរយ។ ការអំពាវនាវជាច្រើនត្រូវបានធ្វើឡើងនៅក្នុងព្រឹទ្ធសភា ដើម្បីចាត់វិធានការលើប្រព័ន្ធកំណត់តម្លៃរបស់ក្រុមហ៊ុនប្រេងទាំងនេះ។ នៅខែកញ្ញា ឆ្នាំ ២០០៨ នៅពេលដែលក្រុមហ៊ុនប្រេងតូចៗជាច្រើន បានបញ្ចុះតម្លៃ ក៏ប៉ុន្តែ ក្រុមហ៊ុនប្រេងធំៗជាច្រើនមិនបានបញ្ចុះតម្លៃតាមភ្លាមៗនោះទេ ទាំងលេខាផ្នែកថាមពល និងប្រធានាធិបតី អារ៉ូយ៉ូ បានស្នើសុំឱ្យក្រុមហ៊ុនប្រេងជាច្រើនធ្វើការពន្យល់ រដ្ឋមន្ត្រីលេខាផ្នែកថាមពលបានរៀបចំកិច្ចប្រជុំមួយជាមួយភាគីពាក់ព័ន្ធនានា។ នៅ ខែ មករា ឆ្នាំ ២០០៩ ក្រុមការងារនេះបានដាក់បញ្ជូន របាយការណ៍មួយ លុបបំបាត់ក្រុមហ៊ុនប្រេងដែលមានប្រព័ន្ធផ្តាច់មុខ និងការកំណត់តម្លៃខ្ពស់។ នៅក្នុងប្រទេសកម្ពុជារដ្ឋាភិបាល បានបង្កើតគណកម្មាធិការពិសេសក្នុងក្រសួងមួយនៅខែមិថុនា ឆ្នាំ ២០០៨ ដើម្បីពិនិត្យតាមមើលតម្លៃប្រេង ក្នុងគោលបំណងដើម្បីវាយតម្លៃ ប្រសិនបើមានការកំណត់តម្លៃខ្ពស់ ។សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវសុំឱ្យក្រុមហ៊ុនប្រេងនានាបញ្ចុះ តម្លៃ នៅក្នុងឱកាសជាច្រើន ហើយនៅខែកញ្ញា ឆ្នាំ ២០០៨ បានណែនាំ ឱ្យក្រសួងសេដ្ឋកិច្ចជួបជាមួយអ្នកលក់ប្រេង ដើម្បីធ្វើការបញ្ចុះតម្លៃ [៤]។

ប្រតិកម្មទាំងនេះ ផ្តល់ជាយោបល់ថា អតិថិជនជាច្រើនបានដឹងអំពីចលនានៃតម្លៃលក់រាយរបស់ផលិតផលប្រេងនៅក្នុងឆ្នាំ ២០០៨ ដែលនឹងត្រូវគ្រប់គ្រងដោយកត្តាផ្សេងៗ ក្រៅពីកំលាំងផ្សារ ហើយបានជឿថា អន្តរាគមន៍របស់រដ្ឋាភិបាលនឹងត្រូវបានកែសម្រួល។ ប្រសិនបើមានអាកប្បកិរិយាឃុបឃិតខ្លះ នោះបញ្ហានេះនឹងក្លាយជាបញ្ហានិយ័តកម្មមួយ។ ម៉្យាងទៀត ប្រសិនបើគ្មានការឃុបឃិតលើតម្លៃចំពោះផ្នែកភាគច្រើនទេ អន្តរាគមន៍របស់រដ្ឋាភិបាលអាចធ្វើឱ្យបញ្ហានេះកាន់តែអាក្រក់ទៅ។

## ការឱ្យនិយមន័យនិងការពន្យល់អំពីបញ្ហា

សំណួរដែលត្រូវបានសួរដោយអ្នកស្រាវជ្រាវដែលបានពិនិត្យមើលប្រធានបទនេះមានបីចំណុច :

(១) តើវាត្រូវការរយៈពេលប៉ុន្មានដែលបំរែបំរួលតម្លៃប្រេងឆៅនៅលើទីផ្សារពិភពលោក មានឥទ្ធិពលលើតម្លៃប្រេងលក់រាយនៅទីផ្សារក្នុងស្រុក?

(២) តើបម្រែបម្រួលលើតម្លៃទាំងនេះ ត្រូវបានបញ្ជូនទាំងស្រុងទៅដល់អតិថិជនឬទេ?

(៣) តើគម្លាតចំពោះការឆ្លើយតបដូចគ្នាក្តី បើសិនជាតម្លៃកំពុងកើនឡើងឬថយចុះ?

ការសិក្សាភាគច្រើនមានចំណាប់អារម្មណ៍ទៅនឹងចលនានៃតម្លៃប្រេងសាំងលក់រាយ ហើយជាផ្នែកមួយនៃតួសេចក្តីនៃអត្ថបទ ស្តីអំពីផលប៉ះពាល់នៃបំរែបំរួលតម្លៃរបស់ធាតុចូល (ដែលត្រូវបានប្រើប្រាស់ដើម្បីផលិតផលិតផលសម្រេច) លើតម្លៃលក់រាយរបស់ផលិតផលសំរេច។ ការសិក្សាមួយបានពិនិត្យមើលលើបំរែបំរួលតម្លៃនៃទំនិញអ្នកប្រើប្រាស់ចំនួន ៧៧ និងទំនិញអ្នកផលិតចំនួន ១៦៥ ហើយបានរកឃើញថា តម្លៃទាំងនេះមានទំនោរកើនឡើងលឿន ហើយថយចុះយឺត។ ការសិក្សានេះបានរកឃើញថា តម្លៃបន្ទាន់ ដែលឆ្លើយតបទៅនឹងការកើនឡើងនៃថ្លៃដើមរបស់ធាតុចូល មានចំនួនទ្វេដងនៃតម្លៃដែលឆ្លើយតបទៅនឹងការថយចុះនៃថ្លៃដើមរបស់ធាតុចូល។ ការសិក្សានេះក៏បានអះអាងផងដែរថា កាលណា មានអន្តរការីកាន់តែច្រើននៅក្នុងបណ្តាញផ្គត់ផ្គង់នោះក៏មានភាពខុសគ្នាកាន់តែច្រើនឡើងដែររវាងការកើនឡើងនិងការថយចុះនៃតម្លៃ។ ក៏ប៉ុន្តែ ការសិក្សានេះក៏បានរកឃើញផងដែរថា កាលណាមានអស្ថេរភាពថ្លៃកាន់តែច្រើន នោះភាពខុសគ្នាលើល្បឿននៃការឆ្លើយតបលើតម្លៃក៏មានកាន់តែតូច [៥]។

នៅក្នុងវិស័យប្រេង ការសិក្សាមួយចំនួន (ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ជាច្រើន) បានរកឃើញថា តម្លៃលក់រាយឆាប់ប្រែប្រួលទៅតាមការកើនឡើងនៃតម្លៃប្រេងឆៅជាងពេលដែល

ថ្លៃប្រេងឆៅថយចុះ ។ ដោយពេលវេលាគ្រប់គ្រាន់ បម្រែបម្រួលនៃតម្លៃទំនងជាត្រូវបានបញ្ជូន ទាំងស្រុងទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ ។ ក៏ប៉ុន្តែ ការសិក្សាមួយចំនួនតូច ក៏បានធ្វើការសន្និដ្ឋាន ផ្ទុយគ្នាផងដែរ ៖ នៅក្នុងការសិក្សាចំនួនពីរ តម្លៃដែលវាកើនឡើងលឿនដូចវាធ្លាក់ចុះតម្លៃដែលវាធ្លាក់ចុះលឿនជាងវាកើនឡើង ។ បច្ចេកទេសវិភាគខុសគ្នានិងសំណុំទិន្នន័យខុសគ្នាដែលបានប្រើប្រាស់មានការសន្និដ្ឋានខុសគ្នា ។ អ្នកនិពន្ធម្នាក់បានប្រើប្រាស់សំណុំទិន្នន័យដូចគ្នានៅក្នុងសហរដ្ឋអាមេរិក និងបានអនុវត្តនូវវិធីសាស្ត្រពីរផ្សេងគ្នា ហើយបានរកឃើញថា មានការសន្និដ្ឋានខុសគ្នាទាំងស្រុង ផ្អែកលើវិធីសាស្ត្រដែលគេបានប្រើ [៦] ។ នៅក្នុងការសិក្សាអំពីបាតុភូតនេះ ចលនានៃតម្លៃត្រូវបានបែងចែកបន្ថែមទៅក្នុងដំណាក់កាលផ្សេងៗក្នុងបណ្តាញផ្គត់ផ្គង់ ។

នៅក្នុងស្ថានភាពជាច្រើនដែលអ្នកស្រាវជ្រាវជាច្រើនជឿថា ពួកគេបានរកឃើញថាតម្លៃកើនឡើងលឿនជាងថយចុះ ការពន្យល់ជាច្រើនត្រូវបានលើកឡើង ។

- *ខ្វះការប្រកួតប្រជែង* ។ ការពន្យល់មួយដែលបានលើកឡើងអំពីការព្រួយបារម្ភខ្លាំងបំផុត គឺកើតចេញពីក្រុមហ៊ុនប្រេងមួយចំនួនតូច ដែលកំពុងគ្រប់គ្រងទីផ្សារ និងយល់ព្រមដោយស្ងៀមស្ងាត់មិនបញ្ចុះតម្លៃលឿន ។ ពិចារណាលើប្រទេសមួយដែលគ្មានរោងចក្រចំរាញ់ ។ នៅពេលដែលតម្លៃនៃផលិតផលប្រេងលើពិភពលោកកើនឡើង ក្រុមហ៊ុនរកទីផ្សារប្រេងបង្កើនតម្លៃលក់រាយ ដើម្បីធានាថាប្រាក់ចំណូលរបស់ពួកគេមិនធ្លាក់ចុះ គឺថា ពួកគេអាចប្រឈមនឹងការខាតបង់ ប្រសិនបើពួកគេមិនកែតំរូវតម្លៃឱ្យបានលឿនទេនោះ ។ នៅពេលដែលតម្លៃនៃផលិតផលចំរាញ់ធ្លាក់ចុះនៅលើទីផ្សារពិភពលោក ប៉ុន្តែ ទំហំនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនរកទីផ្សារប្រេងមិនធ្លាក់ចុះ ហើយសំរាប់ការធ្វើអតិបរមាកម្មប្រាក់ចំណេញ វានឹងមានន័យគ្រប់គ្រាន់ក្នុងការរក្សាតម្លៃអោយនៅខ្ពស់ដដែល រហូតដល់មានក្រុមហ៊ុនមួយឬពីរចាប់កាត់បន្ថយតម្លៃលក់រាយរបស់ក្រុមហ៊ុនដែលនៅសេសសល់ ។ នៅក្នុងទីផ្សារដែលមានការប្រកួតប្រជែងខ្លាំង គេនឹងចាប់ផ្តើមកាត់បន្ថយតម្លៃភ្លាម ដើម្បីពង្រីកភាគហ៊ុនទីផ្សារ ហើយអ្នកផ្សេងទៀតធ្វើតាម ។ នៅក្នុងទីផ្សារដែលមានតែក្រុមហ៊ុនមានចំនួនកំណត់ ហើយគ្មានការប្រកួតប្រជែងគ្រប់គ្រាន់ វាអាចនឹងមានកិច្ចព្រមព្រៀងដែលមិនបាននិយាយ និងមិនបានសរសេរជាលាយលក្ខណ៍អក្សរ មិនកាត់បន្ថយ ហើយតម្លៃអាចនៅតែខ្ពស់រយៈពេលយូរ និងធ្លាក់ចុះយឺតជាងពេលដែល តម្លៃកើនឡើងក្នុងខណៈដែលតម្លៃលើពិភពលោកកើនឡើង ។
- *ចំណេះដឹងរបស់អ្នកប្រើប្រាស់ស្តីពីការប្រែប្រួលតម្លៃមានតិចតួច* ។ ក្រុមហ៊ុនជាច្រើនក៏អាចកេងប្រវ័ញ្ចលើចំណេះដឹងមិនគ្រប់គ្រាន់របស់អ្នកប្រើប្រាស់អំពីថាតើនរណាកំពង់កំណត់តម្លៃ ថ្លៃប៉ុន្មាន នៅពេលណា និងនៅទីកន្លែងណា ។ វាត្រូវការពេលវេលានិងកិច្ចខិតខំប្រឹងប្រែងដើម្បីទៅទស្សនាហាងជាច្រើន ឬស្ថានីយ៍ប្រេងឥន្ធនៈ ប្រៀបធៀបតម្លៃ និងជ្រើសរើសអ្នកលក់ដែលលក់ក្នុងតម្លៃទាបបំផុត ។ អ្នកប្រើប្រាស់ជាច្រើន អាចព្យាយាមប្រឹងប្រែងស្វែងរកជំរើសដែលកាន់តែល្អប្រសើរ នៅពេលដែលតម្លៃកំពុងកើនឡើងជាងនៅពេលដែលតម្លៃដែលកំពុងធ្លាក់ចុះ ជាសក្តានុពល គឺការពង្រឹងបាតុភូតនៃកាំជ្រួចនិងរោមសត្វ ។ ប្រសិនបើថ្លៃចំណាយលើការស្វែងរកអ្នកលក់ដែលមានតម្លៃទាបបំផុត មានកំរិតខ្ពស់ (ឧទាហរណ៍ ប្រសិនបើតម្លៃមិនត្រូវបានគេដាក់បង្ហាញច្បាស់លាស់) នៅពេលនោះវាកាន់តែមានលក្ខណៈងាយស្រួលសម្រាប់អ្នកលក់ក្នុងការរក្សាតម្លៃអោយនៅខ្ពស់ដដែល ។ ផ្ទុយទៅវិញ អ្នកលក់ដុំ អាចជាអ្នកទិញដែលពិបាក ។ ជាពិសេស នៅក្នុងតំបន់ដែលទីផ្សារអនាគត ព័ត៌មានអំពីតម្លៃអាចរកបាន ហើយបម្រែបម្រួលនៃតម្លៃប្រេងឆៅ និងផលិត-ផលចំរាញ់មានឥទ្ធិពលយ៉ាងលឿនទៅលើតម្លៃប្រហែល នៅផ្នែកផ្សេងៗនៃបណ្តាញផ្គត់ផ្គង់លក់រាយ ។
- *ការប្រមូលស្តុកទុន* ។ ប្រសិនបើអ្នកប្រើប្រាស់ទិញកាន់តែច្រើន ដោយគិតថាតម្លៃនឹងកើនឡើងថែមទៀតនោះ បញ្ជីសារពើភ័ណ្ឌនឹងត្រូវថយចុះកាន់តែលឿន ហើយតម្លៃនឹងកើនឡើងកាន់តែលឿនដែរ ។ ការទិញដែលមាន លក្ខណៈស្លន់ស្លោក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បានបណ្តាលឱ្យមានកង្វះខាតប្រេងនៅក្នុងប្រទេសមួយចំនួន ដែលរដ្ឋាភិបាលត្រួតពិនិត្យលើតម្លៃដែលនាំឱ្យមានកង្វះខាតប្រេងនិងធ្វើឱ្យតម្លៃឡើងខ្ពស់នៅលើទីផ្សារងងឹត ។ ម្យ៉ាងទៀត ប្រសិនបើអ្នកប្រើប្រាស់ពន្យាការទិញនៅពេលដែលតម្លៃកំពុងធ្លាក់ចុះ (ដោយសារតែពួកគេរំពឹងថា កាលណាពួកគេរង់ចាំកាន់តែយូរ តម្លៃនឹងកាន់តែធ្លាក់ចុះ) នោះការដាក់ទំនិញបំពេញបន្ថែមក្នុងបញ្ជីសារពើភ័ណ្ឌត្រូវយឺតយ៉ាវ ហើយតម្លៃថយចុះកាន់តែយឺតផងដែរ ។
- *ការកែតំរូវបញ្ជីសារពើភ័ណ្ឌ* ។ ក្រុមហ៊ុនប្រេងជាច្រើននឹងធ្វើនូវអ្វីដែលពួកគេអាចធ្វើបាន ដើម្បីចៀសវាងអស់ប្រេងទាំង

អស់គ្នា។ ការថយចុះនៃបរិមាណផ្គត់ផ្គង់ (ដែលបណ្តាល ឱ្យតម្លៃកើនឡើង) អាចធ្វើឱ្យក្រុមមួយបង្កើនតម្លៃលក់ចេញភ្លាម ដើម្បីបន្ថយល្បឿននៃការលក់ និងចៀសវាងអស់ប្រេងចំរាញ់ ជាពិសេស ប្រសិនបើ បញ្ជីសារពើភ័ណ្ឌផ្ទាល់របស់ពួកគេកំពុងតែថយចុះ។ ប្រសិនបើបរិមាណផ្គត់ផ្គង់ មានច្រើន (បណ្តាលឱ្យតម្លៃធ្លាក់ចុះ) ហើយប្រសិនបើ រៀបចំបញ្ជីសារពើភ័ណ្ឌលើកំរិតធម្មតា វានាំឱ្យមានថ្លៃចំណាយបន្ថែមពាក់ព័ន្ធបន្តិចបន្តួច មានការលើកទឹកចិត្តតិចតួចក្នុងការបញ្ចុះតម្លៃឱ្យបានលឿន។

- *ស្រោចស្រង់ការខាតបង់*។ នៅពេលដែលតម្លៃកើនឡើង យ៉ាងលឿន (ដោយសារតែការរំខានជាលក្ខណៈរូបវ័ន្តចំពោះការផ្គត់ផ្គង់ បរិមាណតំរូវការកើនឡើងលឿនជាងបរិមាណផ្គត់ផ្គង់ ។ល។) អ្នកផលិតនិងអ្នកលក់ដុំ អាចនឹងទទួលការខាតបង់។ រយៈពេលនៃតម្លៃធ្លាក់ចុះផ្តល់នូវឱកាសមួយ ដើម្បីស្រោចស្រង់ការខាតបង់ផ្នែកពាណិជ្ជកម្ម ដែលបណ្តាលមកពីផលប៉ះពាល់នៃតម្លៃតាមរយៈការរក្សាតម្លៃអោយនៅខ្ពស់ និងទ្រទ្រង់ ដល់ទំហំនៃប្រាក់ចំណេញកាន់តែខ្ពស់។

## ការឆ្លើយតប

ទោះជាការវិភាគលើស្ថិតិដែលមានលក្ខណៈស្មុគ្រស្មាញខ្លាំងក៏ដោយ ក៏អ្នកស្រាវជ្រាវជាច្រើននៅសហរដ្ឋអាមេរិក និងនៅប្រទេសអភិវឌ្ឍន៏ដទៃទៀត មានការលំបាកក្នុងការឈានដល់ការស្រុះស្រួលមតិគ្នាមួយ ដែលសំលឹងមើលថាតើតម្លៃប្រេងកើនឡើងលឿនជាងធ្លាក់ចុះឬយ៉ាងណា។ បញ្ហានេះអាចជាការបង្ហាញមួយ ដែលកំណត់ព្រំដែនលើការប្រកួតប្រជែងនៃទីផ្សារ ប្រសិនបើវាកើតមានទាំងអស់ មានទំហំតូចនៅក្នុងប្រទេសទាំងនេះ មួយផ្នែកដោយសារតែបទបញ្ញត្តិតឹងរឹង គ្រប់គ្រងទៅលើអាកប្បកិរិយាប្រឆាំងនឹងការប្រកួតប្រជែង។ មានភស្តុតាងកាន់តែច្បាស់ដែលបំរែបំរួលនៃតម្លៃជាចុងក្រោយត្រូវបានបញ្ជូនទាំងស្រុងទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ។ អ្នកប្រើប្រាស់ជាច្រើន អាចមានទស្សនៈនៃកាំជ្រួចនិងរោមសត្វ សូម្បីតែនៅពេលដែលបាតុភូតនេះមិនកើតឡើងក៏ដោយ ពីព្រោះគំលាតនៃតម្លៃមិនអាចចៀសផុតទៅនៅលើទីផ្សារទាំងអស់ ហើយពីព្រោះ បន្ទាប់ពីរយៈពេលមួយដែលតម្លៃឡើងខ្ពស់គួរឱ្យកត់សំគាល់នោះ អ្នកប្រើប្រាស់ជាច្រើនអន្ទះអន្ទែងចង់ឃើញតម្លៃធ្លាក់ចុះវិញ។ វាជាការសំខាន់ដែលត្រូវឱ្យមានយុទ្ធនាការយល់ដឹងជាសាធារណៈ ដើម្បីកុំឱ្យទស្សនៈខុសឆ្គងនេះនាំអោយរៀបចំគោលនយោបាយខុស។

ជំហានដ៏សំខាន់មួយ កំពុងតែពង្រឹងសិទ្ធិអំណាចអ្នកប្រើប្រាស់តាមរយៈការផ្តល់ឱ្យពួកគេនូវព័ត៌មានអំពីតម្លៃ។ តាមវិធីនេះ ថ្លៃចំណាយក្នុងការស្វែងរកតម្លៃដែលកាន់តែទាប អាចត្រូវបានកាត់បន្ថយ។ អាទិភាពដំបូង គឺតំរូវអោយស្ថានីយ៏ប្រេងឥន្ធនៈទាំងអស់ដាក់បង្ហាញតម្លៃលក់នៅក្តារបង្ហាញ ដោយប្រើទំហំអក្សរដែលអាចមើលឃើញច្បាស់ពីដងផ្លូវ ហើយ*អនុវត្តច្បាប់នេះ*។ អ្នកបើកបរយានយន្ត អាចទទួលបានព័ត៌មានអំពីតម្លៃនៅពេលដែលពួកគេបើកបរ សូម្បីតែនៅពេលដែលពួកគេមិនចូលចាក់ប្រេងក៏ដោយ។

ជំហានមួយទៀត គឺត្រូវផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានតម្លៃប្រេងក្នុងអតីតកាល។ ឧទាហរណ៏មួយអំពីរបៀបដែលរដ្ឋាភិបាលមួយបានធ្វើគឺប្រទេសតង់ហ្សានី។ រដ្ឋាភិបាលនេះ បានធ្វើសេរីភាវូបនីយកម្មវិស័យប្រេងក្នុងឆ្នាំ ២០០០។ នៅឆ្នាំ ២០០៧ អាជ្ញាធរនិយ័តកម្មប្រើប្រាស់ថាមពលនិងទឹកប្រទេសតង់ហ្សានី (EWURA) បានធ្វើការស៊ើបអង្កេតមួយ (ស្នើសុំយោបល់តាមរយៈ បណ្តាញឃោសនាចំរុះ និងរៀបចំសាវនាការសាធារណៈមួយ) លើកាលៈទេសៈដែលនាំអោយមានការកើនឡើងនៃតម្លៃរួម មួយដែលបានកើតឡើងនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០០៧។ ការស៊ើបអង្កេតនេះ មិនបានរកឃើញភស្តុតាងច្បាស់លាស់អំពីការឃុបឃិតលើតម្លៃនោះទេ។ ក៏ប៉ុន្តែ របាយការណ៏លទ្ធផលស៊ើបអង្កេតនេះបានយោងលើផ្នែកជាច្រើនដែលខ្វះខាតបណ្តាញផ្គត់ផ្គង់។ អនុសាសន៏មួយ គឺតំរូវអោយស្ថានីយប្រេងឥន្ធនៈទាំងអស់ "បិទផ្សាយនៅលើក្តារដែលអាចមើលឃើញច្បាស់អំពីតម្លៃដែលបានកំណត់លើផលិតផលប្រេងសំរាប់លក់ចេញ នៅលើទីធ្លារបស់ខ្លួន។ ដើម្បីជំរុញឱ្យការប្រកួតប្រជែងកាន់តែមានប្រសិទ្ធិភាព EWURA បានចាប់ផ្តើមប្រកាសផ្សាយ នៅលើវេបសាយរបស់ខ្លួនអំពីតម្លៃ"វិភាគ"លក់រាយ (តម្លៃនេះត្រូវបានចាត់ទុកថា សមហេតុផលផ្អែកលើកំរិតតម្លៃនាំចូលដូចគ្នា) ព្រមទាំងតម្លៃ ខ្ពស់បំផុត កំណត់ ៧,៥ ភាគរយលើតម្លៃវិភាគ នៅក្នុងតំបន់ខុសៗ គ្នាក្នុងប្រទេស [៤]។

ក្នុងចំណោមប្រទេសជិតខាងរបស់កម្ពុជា ការិយាល័យគោលនយោបាយថាមពលនិងផែនការរបស់ប្រទេសថៃ(EPPO) បិទផ្សាយតម្លៃកើនឡើងនៃផលិតផលប្រេងនិមួយៗនៅលើកាសែតបាងកកប្រចាំថ្ងៃ។ ការចំរាញ់កាលពីមុន តម្លៃលក់ដុំ និងតម្លៃលក់រាយ ព្រមទាំងពន្ធនិងការកំណត់តម្លៃទាំងអស់ ត្រូវបានបង្ហាញ

ដាច់ដោយឡែកពីគ្នាដែលមានចំនួនសរុប ១១ផលិតផល [៧] ។ កិច្ចប្រឹងប្រែងចូលរួមក្នុងការប្រមូលព័ត៌មានដ៏ច្រើន អាចពិចារណាបាន ។ ក្រៅពីនេះ តម្លៃលក់ដុំនិងលក់រាយប្រចាំខែនិងពន្ធដែលប្រមូលបានត្រូវបានផ្សាយនៅលើវេបសាយរបស់ EPPO [៨] ។

ការបិទផ្សាយតម្លៃ មានលក្ខណៈកាន់តែងាយស្រួល ប្រសិនបើតម្លៃទាំងនេះត្រូវបានត្រួតពិនិត្យ ។ ប្រសិនបើតម្លៃទាំងនេះមានលក្ខណៈរួមដូចគ្នាទូទាំងប្រទេស និងត្រូវបានផ្លាស់ប្តូរតែម្តងប៉ុណ្ណោះក្នុងមួយខែ នៅពេលនោះ រដ្ឋាភិបាលអាចបិទប្រកាសយ៉ាងងាយស្រួលអំពីតម្លៃសំរាប់ប្រទេសទាំងមូល ។ ក៏ប៉ុន្តែ អភិក្រមក្នុងការកំណត់តម្លៃនេះ ស្ទើរតែមិនដែលធ្វើឱ្យប្រតិបត្តិការទីផ្សារ មានប្រសិទ្ធិភាពនោះដែរ ។ ប្រសិនបើតម្លៃទាំងនេះ ត្រូវបានកំណត់ដោយកំលាំងទីផ្សារ ដូចនៅក្នុងប្រទេសអភិវឌ្ឍន៍ ទាំងអស់ការស្ទាបស្ទង់មួយលើតម្លៃលក់រាយនឹងត្រូវតែបានអនុវត្តបានទៀងទាត់ ។ នាយកដ្ឋានថាមពលរបស់សហរដ្ឋអាមេរិក ធ្វើការស្ទាបស្ទង់កន្លែងលក់ប្រេងសាំង ( ប្រហែល ១១៥000) និងកន្លែងលក់ប្រេងម៉ាស៊ូតនៅទូទាំងប្រទេស និងបិទផ្សាយតម្លៃលក់រាយប្រចាំសប្តាហ៍ [៩] ។ នាយកដ្ឋានថាមពលប្រទេសហ្វីលីពីន ធ្វើការស្ទាបស្ទង់តម្លៃនៅក្នុងទីក្រុងចំនួនបីក្នុងមួយសប្តាហ៍ម្តង ហើយបិទផ្សាយតម្លៃផលិតផលចំនួន៧ តាមក្រុមហ៊ុន [១០] ។ ការបិទផ្សាយតម្លៃក្នុងអតីតកាល គឺគ្មានតម្លៃ ( អ្នកប្រើប្រាស់អាចមើលឃើញពីទំនាក់ទំនងថ្លៃក្នុងអតីតកាល) ហើយមិនគួរមានការលំបាកទេ ពីព្រោះវាទាមទារនូវព័ត៌មានរក្សាទុកដែលគេបានប្រមូលរួចជាស្រេច ។ សំរាប់ប្រទេសកម្ពុជា ការបិទផ្សាយតម្លៃប្រេង សាំង ប្រេងម៉ាស៊ូត និងប្រេងកាត នៅក្នុងប្រទេសសិង្ហបុរី ទាំងតម្លៃគិតជាដុល្លារអាមេរិក និងទាំងក្រោយការប្តូរទៅជាប្រាក់រៀល ក៏អាចជាព័ត៌មានផងដែរ ។

## ការអង្កេត

ទោះបីជាទស្សនៈនៃបំរែបំរួលតម្លៃមិនប្រក្រតី អាស្រ័យលើថាតើ តម្លៃប្រេងកំពុងកើនឡើងឬថយចុះក៏ដោយ ក៏វាមានការលំបាកក្នុងការបង្ហាញឱ្យបានហ្មត់ចត់ថា ទំនាក់ទំនងបែបនេះកើតឡើងដែរ ។ សូម្បីនៅកន្លែងដែលទំនាក់ទំនងបែបនេះអាចត្រូវបានបង្ហាញយ៉ាងសមហេតុផលថានឹងកើតឡើង ការបង្ហាញបែបនេះ វាបណ្តាលមកពីភាពបរាជ័យរបស់ទីផ្សារមួយ ( ក្រុមហ៊ុនជាច្រើនឃុបឃិតគ្នារក្សាតម្លៃឱ្យនៅខ្ពស់ដដែល) កាន់តែមានភាពប្រឈមច្រើនឡើង ។

ទីផ្សារប្រេងរបស់កម្ពុជាមានទំហំតូច ធ្វើឱ្យការប្រកួតប្រជែងតម្លៃកាន់តែលំបាក ។ ក៏ប៉ុន្តែ សូម្បីតែនៅក្នុងទីផ្សារបែបនេះ ការពង្រឹងសិទ្ធិអំណាចអ្នកប្រើប្រាស់តាមរយៈការផ្តល់ព័ត៌មានអំពីតម្លៃបច្ចុប្បន្ននិងអតីតកាល និងការពន្យល់អំពីយន្តការនានាសម្រាប់ការបញ្ជូនតម្លៃដែលជាក់លាក់ទៅកាន់ទីផ្សារកម្ពុជា ជាផ្លូវដ៏វែងមួយ ដើម្បីជំរុញឱ្យមានការប្រកួតប្រជែងក្នុងខណៈដែលកំពុងជួយលុបបំបាត់ចោលនូវទស្សនៈយល់ខុសគំលាតតម្លៃស្របច្បាប់ ។

## ឯកសារយោង


[១] *កាសែតភ្នែមបូឡាដេលី* ឆ្នាំ ២០០៨ ។ "សម្រាប់មួយចំនួន ការថយចុះនៃតម្លៃប្រេងមិនគ្រប់គ្រាន់" ថ្ងៃទី ២៣ ខែតុលា ។

[២] ធនាគារពិភពលោកឆ្នាំ ២០០៩ ។ "នាំយកផលិតផលប្រេងទៅកាន់ទីផ្សារ" សេចក្តីសង្ខេបអំពីវិស័យប្រេងលេខ ១៦ ។

[៣] ការប្រណាំង ឆ្នាំ ២០០៨ ។ "សភាអាមេរិក ការកំណត់តម្លៃឧស្ម័នត្រូវបានគេស្តីបន្ទោសស្មើគ្នា ។" ថ្ងៃទី ៦ ខែសីហា

[៤] ម៉ាសាមី កូជីម៉ា ។ ចេញផ្សាយហើយ ។ "ការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងអស្ថេរភាពនៃតម្លៃប្រេង : បទពិសោធន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៤៩ ។"

[៥] អេស កែល្បមែន ឆ្នាំ ២000 ។ "តម្លៃកើនឡើងលឿនជាងធ្លាក់ចុះ" *ព្រឹត្តិបត្រសេដ្ឋកិច្ចនយោបាយ* ១0៨(៣) : ៤៦៦-៥0២ ។

[៦] ឌី ស៊ីន ឆ្នាំ ១៩៩២ ។ "តើតម្លៃផលិតផល ឆ្លើយតបស្របគ្នាទៅនឹងបំរែបំរួលនៃតម្លៃប្រេងឆៅដែរឬទេ?" ការសិក្សាស្រាវជ្រាវលេខ ៦៨ របស់វិទ្យាស្ថានប្រេងចំរាញ់អាមេរិក

[៧] www.eppo.go.th/petro/price/index.html.

[៨] www.eppo.go.th/info/index_prices.html.

[៩] http://tonto.eia.doe.gov/dnav/pet/pet_pri_gnd_dcus_nus_w.htm.

[១០] www.doe.gov.ph/OPM/Pumpprices.htm.



**សំរាប់ព័ត៌មានលំអិត សូមទាក់ទង**

**លោក ប៊ុន វាសនា**

**មន្ត្រីហេដ្ឋារចនាសម្ព័ន្ធ**

**អ៊ីម៉ែល: vbun@worldbank.org ឬ**

**លោកស្រី មាសាមី កូជីមា**

**ប្រធានក្រុមអភិវឌ្ឍន៍ថាមពល**

**អ៊ីម៉ែល: mkojima@worldbank.org**